ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ.......................................................

# សុន្ទរកថាបើក
# លោកជំទាវ នាង ច័ន្ទថាណា ទេសាភិបាលរងធនាគារជាតិនៃកម្ពុជា
# ថ្លែងក្នុងពិធីបើកសន្និសីទម៉ាក្រូសេដ្ឋកិច្ចប្រចាំឆ្នាំលើកទី៣ ស្ដីពី
# "វិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា៖ ភាពលានុវត្តភាព និងហានិភ័យ"
# នៅសណ្ឋាគារឡឺរ៉ូយ៉ាល់ ភ្នំពេញ ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៦

សូមគោរព ៖

ឯកឧត្ដម លោកជំទាវ លោក លោកស្រី ជាទីមេត្រី!

ថ្ងៃនេះ តាងនាម ឯកឧត្ដម ជា ចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជា ខ្ញុំមានកិត្តិយសនិងសេចក្ដីសោមនស្សរីករាយជាអនេក ដែលបានចូលរួមក្នុងសន្និសីទម៉ាក្រូសេដ្ឋកិច្ចប្រចាំឆ្នាំ២០១៦ របស់ធនាគារជាតិនៃកម្ពុជា ។ នេះគឺជាលើកទី៣ហើយ ដែលសន្និសីទម៉ាក្រូសេដ្ឋកិច្ច ត្រូវបានរៀបចំឡើង ក្នុងគោលបំណងរួមចំណែកពង្រឹងនិងអភិវឌ្ឍសមត្ថភាពស្រាវជ្រាវ និងផ្ដល់ជាវេទិកាដល់អ្នករៀបចំគោលនយោបាយ តួអង្គពាក់ព័ន្ធសំខាន់ៗក្នុងវិស័យឯកជន សេដ្ឋវិទូ អ្នកស្រាវជ្រាវ និងនិស្សិត ដើម្បីពិភាក្សាផ្លាស់ប្ដូរយោបល់និងបទពិសោធន៍ទៅលើប្រធានបទទាក់ទងនឹងបញ្ហាម៉ាក្រូសេដ្ឋកិច្ចសំខាន់ៗ ដែលអាចជាបញ្ហាប្រឈមដល់សេដ្ឋកិច្ច និងស្វែងរកដំណោះស្រាយសម្រាប់ជាធាតុចូលក្នុងការរៀបចំគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សំដៅបន្តគាំទ្រកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងបរិយាប័ន្ន ។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ឯកឧត្ដម លោកជំទាវ លោក លោកស្រី ជាតំណាងមកពីក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាល វិស័យឯកជន និងដៃគូអភិវឌ្ឍន៍នានា ដែលបានឆ្លៀតឱកាសដ៏មានតម្លៃចូលរួមក្នុងសន្និសីទរបស់យើងនាពេលនេះ ។ ខ្ញុំ



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

មានជំនឿថា វត្តមានរបស់ឯកឧត្តម លោកជំទាវ លោក លោកស្រី នឹងញុំាងឱ្យសន្និសីទនេះ កាន់តែមានភាពសកម្ម និងទទួលបានផ្លែផ្កា គួរជាទីមោទនៈ ។

កាលពីឆ្នាំ២០១៥ កន្លងទៅ ប្រធានបទនៃសន្និសីទរបស់យើងផ្តោតទៅលើ "ការអភិវឌ្ឍទីផ្សារហិរញ្ញវត្ថុ ដើម្បីរួមចំណែកលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល" ។ ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះការរួមចំណែកក្នុងការស្រាវជ្រាវនិងការពិភាក្សាលើប្រធានបទដ៏មានសារៈសំខាន់នេះ ។ លទ្ធផលដែលទទួលបានពីសន្និសីទនាពេលនោះ បានរួមចំណែកក្នុងការរៀបចំគោលនយោបាយអភិវឌ្ឍវិស័យទីផ្សារហិរញ្ញវត្ថុឱ្យកាន់តែរឹងមាំ និងលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ។

នៅឆ្នាំ២០១៦ នេះ ធនាគារជាតិនៃកម្ពុជាបានលើកយកប្រធានបទ ស្តីពី "វិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា៖ កាលានុវត្តភាព និងហានិភ័យ" មកធ្វើជាប្រធានបទស្រាវជ្រាវ និងពិភាក្សា ដើម្បីបង្កើនការយល់ដឹងបន្ថែមពីតួនាទីរបស់វិស័យមីក្រូហិរញ្ញវត្ថុ បញ្ហាប្រឈម និងដំណោះស្រាយជាគោលនយោបាយសម្រាប់បន្តអភិវឌ្ឍវិស័យនេះ ប្រកបដោយចីរភាព ។ ការជ្រើសរើសប្រធានបទនេះធ្វើឡើងស្របពេលដែលរាជរដ្ឋាភិបាលបានរៀបចំសន្និសីទជាតិ ស្តីពី ការអភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ដើម្បីអបអរសាទរសមិទ្ធិផលដែលទទួលបានក្នុងវិស័យមីក្រូហិរញ្ញវត្ថុ ជាពិសេស ក្នុងការបង្កើនបរិយាប័ន្នហិរញ្ញវត្ថុ ការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា និងគាំទ្រកំណើនសេដ្ឋកិច្ច កាលពីខែមីនា កន្លងទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី!**

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមជម្រាបជូន ឯកឧត្តម លោកជំទាវ លោក លោកស្រី ពីប្រវត្តិសង្ខេបនិងស្ថានភាពនៃការអភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ដូចខាងក្រោម៖

វិស័យមីក្រូហិរញ្ញវត្ថុ បានចាប់ផ្តើមអភិវឌ្ឍតាំងពីដើមទសវត្សរ៍ឆ្នាំ១៩៩០មក ដែលដំបូងឡើយ មានរូបភាពជាគម្រោងឥណទានខ្នាតតូចរបស់អង្គការអន្តរជាតិមិនស្វែងរកប្រាក់ចំណេញ ក្នុងបំណងស្តារនីតិសម្បទា ជាពិសេស នៅតាមសហគមន៍ជនបទ ។ សកម្មភាពផ្តល់សេវាមីក្រូហិរញ្ញវត្ថុ បានរីកលូតលាស់ជាបន្តបន្ទាប់ និងបាន